00577766

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification):
02-Aug-2010, 15:43
Kauv Keoratanak

លេខ / No: D337/10

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**លេខសំណុំរឿង: ០០២/១៩-០៩-២០០៧/អ.វ.ត.ក.--ក.ស.ច.ស.**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 08 / 2010
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**
**ចៅក្រម Marcel LEMONDE**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១០**

ភាសា ៖ **ខ្មែរ/បារាំង**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

---

# ដីកាសម្រេចស្តីពីការរៀបចំតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុវត្តតាមវិធាន ២៣ ស្ទួនពីរនៃវិធានផ្ទៃក្នុង

---

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី ជា លាង
លោក Andrew CAYLEY

**<u>ជនត្រូវចោទ</u>**

នួន ជា
ខៀវ សំផន
អៀង សារី
កាំង ហ្គេកអ៊ាវ ហៅ ឌុច
អៀង ធីរិទ្ធ

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

នី ចាន់ឌី ឡោ ជុនធី
គង់ ពិសី ហុង គឹមសួន
យុង ផានិត គឹម ម៉េងឃី
ម៉ុច សុវណ្ណារី ស៊ិន សុវ៉ន
ជេត វណ្ណលី ពេជ អង្គ
Silke STUDZINSKY
Françoise GAUTRY
Isabelle DURAND
Ferdinand Djammen-Nzepa
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Phillipe CANONNE
Elizabeth Rabesandratana
Mahdev MOHAN
Olivier BAHOUGNE
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud
Laure DESFORGES
Christine MARTINEAU
Pascal AUBOIN
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ

**<u>មេធាវីការពារក្តី</u>**

សុន អរុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅស៊ាង Diana ELLIS
ស សូវ៉ាន Jacques VERGÈS
Philippe GRÉCIANO
ការ សាវុត្ថ

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការស៊ើបសួរ លើឈ្មោះ **នួន ជា** និង **ជនដទៃ** ដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យចំពោះ **បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពានបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

បានឃើញវិធាន ២៣(៤) និង វិធាន ២៣ ស្ទួនពីរ(១) និង(២)(ក) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("វិធានផ្ទៃក្នុង")

## ការរំលឹកឡើងវិញពីនីតិវិធី

១. នៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេត បានផ្ញើអនុស្សរណៈអន្តរការិយាល័យជូនអង្គភាពជនរងគ្រោះដោយស្នើឱ្យ៖

"i) *បង្ហាញពីការវាយតម្លៃពីអ្នកសម្រាប់ទំនាក់ទំនងដែលជ្រើសរើសដោយក្រុមតំណាងស្រប ច្បាប់ដែលមានស្រាប់។ និង*

ii) *ផ្តល់អនុសាសន៍នានាទាក់ទិននឹងលទ្ធភាពនៃការមានក្រុមតំណាងស្របច្បាប់រួមគ្នា។*"[1]

២. នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០ អង្គភាពជនរងគ្រោះដែលត្រូវបានប្តូរឈ្មោះថ្មីជាអង្គភាពគាំពារជនរងគ្រោះ (អគជ) បានឆ្លើយតបដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេត ពិចារណាលើចំនុចមួយចំនួនដូចខាងក្រោម៖

[1] **D289** ផែនការក្នុងការរៀបចំការតំណាងតាមផ្លូវច្បាប់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី

(i) កុំធ្វើសកម្មភាពណាមួយដែលរំខានដល់ក្រុមតំណាងស្របច្បាប់ដែលមានស្រាប់ ឬការជ្រើសរើសមេធាវី

(ii) ធ្វើការបែងចែកដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ ដោយផ្អែកលើមូលដ្ឋានអ្នកតំណាងដែលមាននៅតាមខេត្ត

(iii) ណែនាំមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង អ.គ.ជ ឱ្យធ្វើការរួមគ្នា បន្តកំណត់អត្តសញ្ញាណ និងទំនាក់ទំនងជនរងគ្រោះមិនទាន់មានតំណាង ដែលចូលក្នុងក្រុមមេធាវីដែលមានស្រាប់ ដែលបានបង្ហាញឱ្យឃើញពីលទ្ធភាព និងគោលបំណងរបស់ខ្លួន ក្នុងការទទួលយកកូនក្តីបន្ថែមទៀត ដើម្បីធ្វើជាតំណាងស្របច្បាប់ និងឱ្យធ្វើរបាយការណ៍ត្រឡប់មកវិញ ក្នុងរយៈពេលមួយជាកំណត់អំពីកិច្ចខិតខំប្រឹងប្រែងទាំងនេះ[2]។

៣. នៅក្នុងអនុស្សរណៈអន្តរការិយាល័យរបស់ខ្លួន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០[3] សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងពីគោលបំណងរបស់ខ្លួនពីការធានាថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ អាចមានតំណាង[4]។

៤. នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១០ អ.គ.ជ បានជូនដំណឹងសហចៅក្រមស៊ើបអង្កេតថា ខ្លួនបានទទួលស្គាល់សមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅប្រទេសកម្ពុជា (ស.ជ.ខ.ក.ក) កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១០[5] និងថាប្រធានសមាគមបានបង្ហាញពីគោលបំណងកំណត់ទំហំនៃតំណាងស្របច្បាប់ដែលធ្វើឡើងដោយមេធាវីរបស់សមាគម លោក នី ចាន់ឌី ត្រឹមសមាជិករបស់សមាគមចំនួន ៨៤ នាក់[6] និង សូមបញ្ជាក់ថា៖

- សមាជិក ៣រូប[7] ក្នុងចំណោមសមាជិកជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស.ជ.ខ.ក.ក ចំនួន ៨៤ នាក់ ទំនងជាបានប្រគល់សិទ្ធិតំណាងដោយអាណត្តិជូនមេធាវីផ្សេងទៀតរួចហើយ។

---

[2] **D289/1** បញ្ហាទាក់ទិននឹងការបង្កើតក្រុមដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងស្របច្បាប់ (សំណុំរឿង ០០២) កថា. ២៤។

[3] **D337/6**

[4] នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងភាគីនានាថា ខ្លួននឹងចេញដីកាឱ្យបានឆាប់តាមដែលអាចធ្វើបាន បន្ទាប់ពីមេធាវីដែលត្រូវបានតែងតាំងដោយ អ.វ.ត.ក ត្រូវបានជ្រើសរើសរួច (D337/7)។

[5] D337/8 អនុស្សរណៈអន្តរការិយាល័យរបស់អង្គភាពគាំពារជនរងគ្រោះជូនសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការចុះបញ្ជីសមាគមជនរងគ្រោះនិងផលវិបាកនៃបញ្ហាផ្នែកតំណាងតាមផ្លូវច្បាប់, D337/8.1 លិខិតទទួលស្គាល់ពីអង្គភាពគាំពារជនរងគ្រោះ

[6] D337/8.3 លិខិតរបស់ប្រធានសមាគម។

[7] 09-VU-02064, 09-VU-02097 et 09-VU-02185

- ក្នុងចំណោមសមាជិករបស់សមាគមដែលមិនមានឈ្មោះនៅក្នុងបញ្ជីតំណាងដែលរៀបចំឡើងដោយប្រធានសមាគមនោះ មាន ៣៥ នាក់ ត្រូវបានជ្រើសរើសឲ្យតំណាងដោយក្រុមមេធាវីផ្សេងទៀតរួចហើយ និងរហូតមកទល់ពេលនេះ មាន ២៤ នាក់ ដែលមិនទាន់មានតំណាងនៅឡើយ។

៥. សហចៅក្រមស៊ើបអង្កេត បានទទួលដំណឹងពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអំពីគោលបំណងរបស់ខ្លួនក្នុងការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀត[8]។

៦. នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ដោយផ្អែកលើការជូនដំណឹងពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអំពីគោលបំណងរបស់ខ្លួនក្នុងការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀត អ.គ.ជ[9] បានផ្តល់ជូនសហចៅក្រមស៊ើបអង្កេត នូវសំណើសុំចាត់តាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងបញ្ជីឈ្មោះអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់មានតំណាងនៅឡើយ បន្ទាប់ពីការចាត់តាំងមេធាវីនេះ (សូមអានឧបសម្ព័ន្ធ)។

## សំអាងហេតុនៃសេចក្តីសម្រេច

៧. ដោយអនុវត្តតាមវិធាន ២៣ ស្ទួនពីរ (២)(ក) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលត្រូវបានធ្វើវិសោធនកម្ម នៅក្នុងកិច្ចប្រជុំពេញអង្គលើកចុងក្រោយ *"រាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវបានតំណាងដោយមេធាវី យ៉ាងយូរបំផុតត្រឹមពេលចេញដីកាដំណោះស្រាយ"* និង *"សហចៅក្រមស៊ើបអង្កេត ត្រូវ (...) ចេញដីកាដែលសមស្រប សម្រាប់គោលដៅនេះ"*។ ហេតុដូច្នេះ វិធាន ២៣(៤) នៃ

---

[8] សហចៅក្រមស៊ើបអង្កេត បានទទួលលិខិតដូចតទៅ៖

- D337/9.2 : លិខិតរបស់មេធាវី នី ចាន់ឌី និង Lyma NGUYEN ចុះថ្ងៃទី ០៧-០៦-២០១០
- D337/9.3 : លិខិតលើកទី ២ របស់មេធាវី នី ចាន់ឌី និង Lyma NGUYEN ចុះថ្ងៃទី ០៧-០៦-២០១០
- D337/9.4 : លិខិតរបស់មេធាវី Olivier BAHOUGNE ចុះថ្ងៃទី ០៧-០៦-២០១០
- D337/9.5 : លិខិតរបស់ក្រុមមេធាវី ដើមបណ្តឹងរដ្ឋប្បវេណី "មេធាវីគ្មានព្រំដែន" ចុះថ្ងៃទី ០៧-០៦-២០១០
- D337/9.6 : លិខិតរបស់មេធាវី នី ចាន់ឌី និង Mahdev MOHAN ចុះថ្ងៃទី ០៨-០៦-២០១០
- D337/9.7 : លិខិតរបស់មេធាវី នី ចាន់ឌី និង Silke STUDZINSKY ចុះថ្ងៃទី ១៨-០៦-២០១០
- D337/9.8 : លិខិតរបស់មេធាវី ជេត វណ្ណលី និងមេធាវី ពេជ អង្គ ចុះថ្ងៃទី ២២-០៦-២០១០
- D337/9.9 : លិខិតរបស់មេធាវី Emmanuel Altit, Emmanuel Jacomy, Julien Rivet និង នី ចាន់ឌី ចុះថ្ងៃទី ២៤-០៦-២០១០
- D337/9.10 : លិខិតរបស់មេធាវី នី ចាន់ឌី និង Lyma NGUYEN ចុះថ្ងៃទី ២៧-០៦-២០១០

[9] D337/9 អនុស្សរណៈអន្តរការិយាល័យ របស់អង្គភាពគាំពារជនរងគ្រោះ ចុះនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០

00577770



វិធានផ្ទៃក្នុង ចែងថា *"សហចៅក្រមស៊ើបអង្កេត អាចចាត់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីជាក្រុម និងចាត់តាំងមេធាវីម្នាក់ឱ្យតំណាងក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ឬចាត់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះចូលជាមួយក្រុមដែលមានស្រាប់"*[10] ។

៨. សហចៅក្រមស៊ើបអង្កេត សូមបញ្ជាក់ថាមានអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន **៣៩៩០** នាក់ នៅក្នុងសំណុំរឿង ០០២។ ក្នុងចំណោមនេះមាន **៣២០១** នាក់ បានប្រគល់សិទ្ធិតំណាងដោយអាណត្តិត្រឹមត្រូវប្រគល់សិទ្ធិឱ្យមេធាវីកម្ពុជា (និងក្នុងករណីខ្លះ មេធាវីអន្តរជាតិ) ឱ្យធ្វើជាតំណាងខ្លួន (សូមមើលបញ្ជីនៅក្នុង**ឧបសម្ព័ន្ធ** ក)។ ការប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះ ត្រូវបានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតដោយ អ.គ.ជ និងបានដាក់ចូលទៅក្នុងសំណុំរឿងជាបន្តបន្ទាប់។ ដីកានាពេលនេះ មានគោលបំណងរៀបចំតំណាងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន **៧៨៩** ដែលមិនទាន់តំណាងនៅឡើយ នៅពេលចេញដីកានេះ។

៩. ទាក់ទិននឹងការចាត់តាំងមេធាវីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាងនេះ សហចៅក្រមស៊ើបអង្កេត បានធ្វើការពិចារណាជាបឋមទៅលើការជ្រើសរើសមេធាវីរួចហើយដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ និងបន្ទាប់មកពីសមត្ថភាពរបស់មេធាវីក្នុងការតំណាងកូនក្តីបន្ថែមទៀត (ផ្អែកលើគោលបំណងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងស្ថានភាពរបស់មេធាវី គឺមានន័យថាទៅលើជំនាញ និងលំនៅដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី) និងចុងក្រោយលើអនុសាសន៍របស់ អ.គ.ជ ដែលមាននៅក្នុងអនុស្សរណៈចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១០។

១០. សូមរំលឹកថា យោងតាមវិធាន ២៣ ស្ទួនពីរ (២) ក) ដើមបណ្តឹងរដ្ឋប្បវេណី នៅតែមានសេរីភាពក្នុងការផ្លាស់ប្តូរមេធាវីរបស់ខ្លួន ដោយការដាក់ពាក្យសុំប្រគល់សិទ្ធិតំណាងដោយអាណត្តិថ្មី ដែលស្ថិតនៅក្រោមការសម្រេចពីសហចៅក្រមស៊ើបអង្កេត ស្របតាមវិធាន ២៣(៤) នៃវិធានផ្ទៃក្នុង និងការតម្រូវឱ្យដាក់សំណើសុំផ្លាស់ប្តូរជូនសហចៅក្រមស៊ើបអង្កេត ស្របតាមវិធាន ២៣ ស្ទួនពីរ (៣) នៃវិធានផ្ទៃក្នុង ក្នុងករណីដែលមេធាវីមុននោះជាមេធាវីចាត់តាំងដោយសហចៅក្រមស៊ើបអង្កេត។

## ១- សមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅប្រទេសកម្ពុជា

១១. យោងតាមវិធាន ២៣ ស្ទួនបី ស.ជ.ខ.ក.ក បានជូនដំណឹងថា មេធាវីរបស់សមាគម គឺ លោក នី ចាន់ឌី មានគោលបំណងធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាសមាជិករបស់សមាគមចំនួន ៨៤

[10] សូមអានវិធាន ២៣ ស្ទួនពីរ (២)

នាក់[11]។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេត កត់សំគាល់ឃើញថា សមាជិក ៣ រូប ក្នុងចំណោម ៨៤ រូប នោះ ត្រូវបានតំណាងរួចហើយដោយមេធាវីផ្សេងរបស់ខ្លួន។ ទោះបីជាមិនមានការចែងច្បាស់ពីករណីលើកលែងដោយវិធាន ២៣ ស្ទួនបី នៃវិធានផ្ទៃក្នុងទាក់ទិននឹងករណីពិសេសបែបនេះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត យល់ឃើញថា ដោយផ្អែកតាមអំណាចទូទៅរបស់ខ្លួនដែលកំណត់ដោយវិធាន ២៣(៤) ខ្លួនអាចបញ្ជាក់ថាកូនក្តី និង មេធាវី បានមានទំនាក់ទំនងគ្នារួចហើយ ទោះបីជាកូនក្តីនោះបានចូលជាសមាជិករបស់សមាគមមួយនៅពេលក្រោយមកទៀត ឬក៏បានចាត់តាំងមេធាវីមួយរូបផ្សេងពីមេធាវីរបស់សមាគមក៏ដោយ ចំពោះអ្វីដែលទាក់ទងនឹងប្រយោជន៍នៃយុត្តិធម៌។

១២. ដោយផ្អែកលើគោលការណ៍ខាងលើ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា គ្រប់សមាជិកទាំងអស់របស់សមាគមដែលបានដាក់ពាក្យប្រគល់សិទ្ធិតំណាងដោយអាណត្តិជូនមេធាវីរួចហើយ រួមទាំងសមាជិកពីររូបដែលមានឈ្មោះនៅក្នុងបញ្ជីដែលផ្តល់ដោយប្រធានសមាគម នឹងត្រូវបានតំណាងដោយមេធាវីដែលខ្លួនបានជ្រើសរើស លើកលែងតែរហូតដល់ពេលដែលពួកគេ ជូនដំណឹងដល់ ស.ច.ស ជាលាយល័ក្ខអក្សរតាមរយៈ អ.គ.ជ ថាខ្លួនសម្រេចយកការតំណាងដោយមេធាវីរបស់សមាគមជនរងគ្រោះដែលខ្លួនជាសមាជិក។

## ២-ការតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមដោយក្រុមមេធាវីដែលមានស្រាប់

សហចៅក្រមស៊ើបអង្កេត បានទទួលយកសំណើរបស់ក្រុមមេធាវីនៅក្នុងលក្ខខណ្ឌដែលកំណត់នៅត្រង់ផ្នែកនៃសេចក្តីសម្រេច និង ក្នុងករណីដែលមិនមានការប្រគល់សិទ្ធិតំណាងដោយអាណត្តិ សម្រេចចាត់តាំងមេធាវីទាំងនេះឲ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣៩ ដែលមានឈ្មោះនៅក្នុង **ឧបសម្ព័ន្ធ គ**។

## ៣-ការតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសល់

សហចៅក្រមស៊ើបអង្កេត ចាត់តាំងលោក-លោកស្រីមេធាវី វ៉ែន ពៅ ជេត វណ្ណលី និង ពេជ អង្គ សមាជិកក្រុមមេធាវីដែលបានចុះកិច្ចសន្យាជាមួយ អ.វ.ត.ក ដោយអនុវត្តតាមវិធាន ១២ នៃវិធានផ្ទៃក្នុង ដើម្បីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥៦៩ ដែលមិនទាន់មានតំណាងនៅឡើយ (**ឧបសម្ព័ន្ធ ឃ**)។

[11] D337/8.3 លិខិតរបស់ប្រធានសមាគម។ សូមអាន ឧបសម្ព័ន្ធ ខ។

## ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត សម្រេច

**បញ្ជាក់ពីការទទួលស្គាល់របស់ខ្លួន** ចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ បានប្រគល់សិទ្ធិតំណាងដោយអាណត្តិជូនត្រឹមត្រូវរួចហើយមកទល់ពេលនេះ (**ឧបសម្ព័ន្ធ ក**)។

**បញ្ជាក់ថា** សមាជិក ៨១ រូប របស់សមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅប្រទេសកម្ពុជា (ស.ជ.ខ.ក.ក) ដែលមានឈ្មោះនៅក្នុងបញ្ជីនៃលិខិតរបស់ប្រធានសមាគម ហើយដែលមិនបានប្រគល់សិទ្ធិតំណាងដោយអាណត្តិដល់មេធាវីផ្សេងទៀត ត្រូវតំណាងដោយមេធាវីរបស់សមាគមនេះ (**ឧបសម្ព័ន្ធ ខ**)។

**ចាត់តាំង** សមាសភាពមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលមានរួចហើយឲ្យធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន **១៣៩** ដូចមានឈ្មោះនៅក្នុង**ឧបសម្ព័ន្ធ គ** នៃដីកានេះ។

**ចាត់តាំង** លោកមេធាវី វ៉ែន ពៅ លោកស្រីមេធាវី ជេត វណ្ណលី និង លោកមេធាវី ពេជ អង្គ ឲ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន **៥៦៩** ដែលមិនទាន់មានតំណាង ដូចមានឈ្មោះនៅក្នុង **ឧបសម្ព័ន្ធ ឃ** នៃដីកានេះ។

**សម្រេចថា** ដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណាដែលមានបំណងចង់ផ្លាស់ប្តូរមេធាវី ត្រូវផ្តល់ការជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១០

**សហចៅក្រមស៊ើបអង្កេត**
**Co-Investigating Judges**
**Co-juges d'instruction**

**Marcel LEMONDE**

យូ ប៊ុនឡេង